សិល្បៈ

The Arts of Writing Khmer Poetry

តែងកំណាព្យ

៣២៥
៨៧

www.yerngshare.blogspot.com

ពេជ្រ ទុំក្រគុំល
PICH TUM KRAVEL

CAMBODIA

www.yerngshare.blogspot.com

៣២៥.៨៧

សិល្បៈតែងកំណាព្យ

និពន្ធដោយ

ឯកឧត្តម ពេជ្រ ឆុំក្រៃទុំលេ

ភ្នំពេញ ២០០២

រក្សាសិទ្ធិ

www.yerngshare.blogspot.com

The Arts of Writing Khmer Poetry

By

Prof. PICH TUM KRAVEL

Phnom Penh 2002

www.yerngshare.blogspot.com

All rights reserved

សិល្បៈតែងកំណាព្យ

អ្នកនិពន្ធ	:	ឯកឧត្តម ពេជ្រ ទុំក្រទុំល
ទទួលខុសត្រូវ និង ចាត់ចែងបោះពុម្ព	:	គីម ពេជ្រពីរឆន់ & ចិន្ត នាគ
បច្ចេកទេសកុំព្យូទ័រ	:	ហ៊ុយ សុខឆេង
បោះពុម្ពនៅរោងពុម្ព	:	អេងពុម្ពខ្មែរ
ទំហំ	:	១៤.០៥ X ២០.០៥
បោះពុម្ពលើកទី១ ចំនួន	:	៥០០ ច្បាប់
ឧបត្ថម្ភបោះពុម្ពដោយ	:	[illegible]

www.yerngshare.blogspot.com

ពុទ្ធសាសនបណ្ឌិត្យ
ចូល
លេខ...ហ៊ាន..ម..ន..
ថ្ងៃទី..ក..ខែ..ត..ឆ្នាំ..ច..
បញ្ជូន.....ប.ណ.ន.....

ឯកឧត្តម ហេង ភុំក្រឌុល

www.yerngshare.blogspot.com

ជីវប្រវត្តិសង្ខេប

កើតថ្ងៃទី 02 មិថុនា ឆ្នាំ 1943 នៅភូមិសសី ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល ។
ជាបុត្ររបស់លោក **ជួន ឈន** និង អ្នកស្រី **ញ៊ួច យ៉ុម** (កសិករ) ។

ឆ្នាំ 2001- : -វិញ្ញាបនបត្រ *Palmes Académiques* ក្រសួងអប់រំ សាធារណរដ្ឋបារាំង

ឆ្នាំ 2001- : -វិញ្ញាបនបត្រព្រឹទ្ធាចារ្យ វប្បធម៌សិល្បៈ រាជបណ្ឌិត្យសភាកម្ពុជា

ឆ្នាំ 1999- : -ទទួលពានរង្វាន់ជ័យលាភី លើកទី ១ នៅប្រទេសកម្ពុជា ផ្នែកតែងនិពន្ធប្រចាំអាស៊ីអាគ្នេយ៍ ។
-ប្រធានគណៈកម្មការស្រាវជ្រាវសិល្បៈ វប្បធម៌ ប្រចាំក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

ឆ្នាំ 1998- : -អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

ឆ្នាំ 1997-1998 : ធ្វើការនៅវិទ្យុអាស៊ីសេរី ក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក ទទួលបន្ទុកសិល្បៈ វប្បធម៌ និង ប្រវត្តិសាស្ត្រកម្ពុជា ។

ឆ្នាំ 1994-1997 : អ្នកនាយកអភិវឌ្ឍន៍វប្បធម៌ និង វិចិត្រសិល្បៈ ។

ឆ្នាំ 1982-1993 : ប្រធាននាយកដ្ឋានសិល្បៈនៃក្រសួងវប្បធម៌ និង ពត៌មាន ។

ឆ្នាំ 1979-1981 : អនុប្រធាននាយកដ្ឋានសិល្បៈនៃក្រសួងឃោសនាការ វប្បធម៌ និង ពត៌មាន ។

ឆ្នាំ 1975-1978 : ទាសករនៅស្រុកឧដុង្គ តំបន់ ៣២ នាសម័យ ប៉ុល ពត ។

ឆ្នាំ 1969-1975 : នាដកនៅអភិរក្សមន្ទីរជាតិនៃទស្សនីយភាព និង ជាសាស្ត្រាចារ្យមហាវិទ្យាល័យសិល្បៈ នាដសាស្ត្រ ។

ឆ្នាំ 1965-1967 : និស្សិតមហាវិទ្យាល័យសិល្បៈនាដសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។

www.yerngshare.blogspot.com

ឆ្នាំ 1963-1964 : និស្សិតនៃសាលាជាតិ ផ្នែក "**ល្ខោនជាតិ**"

ឆ្នាំ 1960-1963 : សិស្សនៅវិទ្យាស្ថានជាតិគរុកោសល្យ ។

ស្តាដែនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

ពុទ្ធសាសនបណ្ឌិត្យ និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្តាដែ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

អង្គការរីហ្សូ កូស៊ី-កៃ វិទ្យាស្ថានបើកទូលាយ

ករុណាខ្មែរ និង **មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្តាដែនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

www.yerngshare.blogspot.com

អារម្ភកថា

កង្វះខាតឯកសារលើវិស័យវប្បធម៌ គឺជាចំណោទដ៏ធំមួយនៅប្រទេសកម្ពុជា ។ ដើម្បីរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រខាងឯកសារវប្បធម៌ ពិសេសខាងផ្នែកសិល្បៈទស្សនីយភាព..... លោក **ពេជ្រ ឆុំគ្រវិល** និង មិត្តភក្តិរបស់លោកជាច្រើននាក់ បានខិតខំជាច្រើនឆ្នាំមកហើយ ធ្វើការសិក្សាស្រាវជ្រាវ ចងក្រងជាឯកសារអំពីរបាំខ្មែរ តន្ត្រី និង ចំរៀងខ្មែរ ល្ខោនច្រើនទម្រង់... ហើយបានបោះពុម្ពជាស្បៀវភៅរួចមួយចំនួនផងដែរ ។ ក្នុងនោះមាន **សិល្បៈតែងកំណាព្យ** ដែលគាត់បានចងក្រងឡើង ដោយយោងតាមឯកសារជាច្រើនដូចជា : មេកាព្យ របស់លោក **អឿង សាយ** ជាគ្រូរបស់គាត់ ពេលដែលគាត់ជាសិស្សរៀននៅវិទ្យាស្ថានជាតិគរុកោសល្យ ក្រុងភ្នំពេញ ។ ឯកសារសំណៅសរសេរដៃរបស់ ឧកញ៉ាសុតន្តប្រីជាឥន្ទ ដែលគាត់ទទួលបានពីលោក **ប៉ុល សំអឿន** គ្រូរបស់គាត់នៅសាលាជាតិផ្នែក ល្ខោន **"ល្ខោនជាតិ"** និង ឯកសារផ្សេងៗទៀតរបស់ក្រសួងអប់រំ របស់ពុទ្ធសាសនបណ្ឌិត និង អ្នកនិពន្ធជំនាន់ចាស់ជាច្រើន ពិសេសគឺបន្ទូល ទូន្មានប្រៀនប្រដៅរបស់សម្តេចសង្ឃរាជ **ជួន ណាត** ក្នុងពេលដែលគ្រូរបស់គាត់គឺលោក **ហាច់ ឆនហាក់** លោក **ឆេង ផុន** លោក **ថាច់ ង្រោច** បាននាំពួកគាត់

www.yerngshare.blogspot.com

ដែលជាសិស្សនៅមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ ផ្នែកខាងសិល្បៈប្រពៃណី ដែលមានរឿង "សូត្រកំណាព្យ"ផងនោះ ទៅសូត្រថ្វាយព្រះអង្គទ្រង់សណ្តាប់(ដើម្បីឆ្លងមតិព្រះអង្គ)នៅមហាកុដិវត្តឧណ្ណាលោម... ដែលជាឱកាសដ៏ល្អ អនុញ្ញាតឱ្យគាត់បានស្តាប់ និង កត់ត្រាទុកនូវបន្ទូលដ៏មានសារៈសំខាន់របស់សម្តេចព្រះសង្ឃរាជ ដែលបានពន្យល់ណែនាំ កែលំអ ចង្អុលបង្ហាញអំពីតន្ត្រី ចំរៀង និង កំណាព្យខ្មែរ ទាំងរបៀបសូត្រ និងរបៀបសរសេរផង ។

គណៈគ្រប់គ្រងមហាវិទ្យាល័យសិល្បៈនាដសាស្ត្រយល់ឃើញថា : កំណាព្យមានសារៈសំខាន់ណាស់ក្នុងជីវិតខ្មែរ ហើយចាស់បុរាណជូនតាខ្មែរក៏បានយកកំណាព្យជាមធ្យោបាយអប់រំ ដោយយករូបភាពកំណាព្យ "ពីរោះត្រចៀក" ដើម្បីងាយស្រួលបញ្ចូលខ្លឹមសារនៃការអប់រំ ទាំងចំណេះដឹង ទាំងចំណេះធ្វើ ទាំងសីលធម៌រស់នៅ ដែលលោកចង់បានឱ្យនៅដក់ជាប់ក្នុងសតិអារម្មណ៍ របស់កុលបុត្រ កុលធីតាខ្មែរគ្រប់រូប ។

ម៉្យាងទៀតកំណាព្យមានឥទ្ធិពលធំធេងណាស់ នៅក្នុងទម្រង់សិល្បៈទស្សនីយភាពខ្មែរ ពោលគឺតន្ត្រី ចំរៀង ក៏ត្រូវការកំណាព្យ រាំក៏ត្រូវការកំណាព្យ ល្ខោនច្រើនទម្រង់: ល្ខោនបាសាក់ ល្ខោនយីកេ មហោរី ល្ខោនពោលស្រី អាប៉ែ អាយ៉ៃ ប្រាមោទ្យទ័យ ស្បែកធំ ល្ខោនខោល ឬ ភាណី ។ [illegible] ប្រការដែលចាំ

www.yerngshare.blogspot.com

បាច់បំផុតនោះ គឺដើម្បីនិពន្ធ និង រៀបរៀងរឿងល្ខោនទៅតាមទម្រង់ល្ខោននានា ដែលមានជាងម្ភៃទម្រង់នៅប្រទេសកម្ពុជានោះ អ្នកនិពន្ធ និងអ្នករៀបរៀងត្រូវតែចេះកំណាព្យ ជាប្រការខានមិនបាន ពិសេសគឺរបៀបសរសេរកំណាព្យខ្មែរ នេះឯង ។

ស្របតាមបំណងប្រាថ្នារបស់គណៈគ្រប់គ្រងមហាវិទ្យាល័យសិល្បៈនាដសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដែលមានគំរោងក្នុងការអប់រំបណ្តុះបណ្តាលធនធានមនុស្ស ពិសេសគឺអ្នកនិពន្ធ និង អ្នកដឹកនាំរឿងល្ខោន ព្រមទាំងកិនិពន្ធផងនោះ... ទើបគណៈគ្រប់គ្រងមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ សំរេចជ្រើសរើសយកស្បៃវរភៅ **សិល្បៈតែខ កំណាព្យ** មកបោះពុម្ពសារជាថ្មី ដោយជំនួយដ៏សប្បុរស របស់អង្គការយូណេស្កូ UNESCO ក្នុងក្តីសង្ឃឹមយ៉ាងមុតមាំថា: កូនស្បៃវរភៅដ៏តូចនេះ នឹងបានរួមចំណែក ផ្តល់ផលប្រយោជន៍ ទោះតិចក្តី ច្រើនក្តី ដល់មាតុភូមិដ៏កំសត់របស់យើង តាមបំណងប្រាថ្នារបស់គណៈគ្រប់គ្រងមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ យើងខ្ញុំមិនខាន ។

ជ.គណៈគ្រប់គ្រងមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ

ព្រឹទ្ធបុរសរង

គីម ពេជ្រតីរនន់

www.yerngshare.blogspot.com

សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទអ្នករៀបរៀងសៀវភៅ **សិល្បៈតែងកំណាព្យ** សូមថ្លែងអំណរគុណចំពោះ - គណៈគ្រប់គ្រងមហាវិទ្យាល័យសិល្បៈនាដសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដែលបានជ្រើសរើសសៀវភៅនេះមកបោះពុម្ពសារជាថ្មី ដើម្បីជាផលប្រយោជន៍ដល់សិស្ស-និស្សិត នៃមហាវិទ្យាល័យសិល្បៈនាដសាស្ត្រផង និង ដល់មិត្តអ្នកអានជាទូទៅផង ទាំងក្នុងពេលបច្ចុប្បន្ន ក៏ដូចទៅអនាគត និង សូមថ្លែងអំណរគុណជាពន្លឺកចំពោះ - អង្គការ យូណេស្កូ UNESCO ដែលបានចំណាយទុនយ៉ាងច្រើន ដើម្បីជួយវិស័យវប្បធម៌ជាតិកម្ពុជា : មានការជួសជុលប្រាសាទបុរាណ ថតឯកសារតន្ត្រី និងចំរៀងបុរាណ ស្រាវជ្រាវដំឡើងរបាំថ្មីទាំងជាតិ និង ជនជាតិ ធ្វើឱ្យរស់ឡើងវិញនូវទម្រង់ល្ខោនដែលបាត់បង់ ទៅជួសជុលគំរូវិចិត្រកម្ម ជួសជុលរូបចម្លាក់បុរាណ ឧបត្ថម្ភការធ្វើបទកថាតាមអាគារសិក្សានានា បោះពុម្ពសៀវភៅ និង ឯកសារជាច្រើន ក្នុងនោះមានទាំងសៀវភៅ **សិល្បៈតែងកំណាព្យ** នេះផងដែរ ។

www.yerngshare.blogspot.com

សូមប្រសិទ្ធិពរ សិរីសួស្តីមហាប្រសើរ ជូនគណៈគ្រប់គ្រងមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និង អង្គការ UNESCO សូមឱ្យបានសមប្រកបតែនឹងជោគជ័យ និង "យស" ជានិច្ច និរន្តរ៍ ។

អ្នករៀបរៀង

www.yerngshare.blogspot.com

ជំរាបជូនអ្នកអាន !

ប្រិយមិត្តអ្នកអានជាទីមេត្រី !

សៀវភៅ **សិល្បៈតែងកំណាព្យ** ដែលប្រិយមិត្តកំពុងតែកាន់នៅដៃនេះ បានបោះពុម្ពពីរលើករួចមកហើយ គឺ :

- លើកទី ១ ឆ្នាំ ១៩៨៥ បោះពុម្ពចំនួន ៥000ក្បាល ជាការផ្សាយរបស់អាគារបោះពុម្ពផ្សាយ " វប្បធម៌ " ។

- លើកទី ២ ឆ្នាំ ១៩៨៨ បោះពុម្ពចំនួន ១0.២00 ក្បាល ជាការផ្សាយរបស់អាគារបោះពុម្ពផ្សាយ " វប្បធម៌ " ដែរ ។ ហើយនេះជាលើកទី ៣ ហើយ ដែលសៀវភៅ **សិល្បៈតែងកំណាព្យ** ត្រូវបានជ្រើសរើសបោះពុម្ពសារជាថ្មីឆ្នាំ ២00១ ដោយគណៈគ្រប់គ្រងមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និង អង្គការយូណេស្កូ UNESCO ប្រចាំនៅកម្ពុជា ចំនួន ៥00 ក្បាល ។

ក្នុងការបោះពុម្ពលើកទី ៣ នេះ ខ្ញុំបាទជាអ្នករៀបរៀង បានធ្វើការកែលំអបន្តិចបន្តួច ដូចជា : កែលំអក្របខាងក្រៅ ដែលពីមុនប្រើដោយគំនូរលាបពណ៌ ដែលឥឡូវត្រូវព្រិល ព្រោក មើលស្ទើរលែងច្បាស់ទៅហើយនោះ ទៅជាប្រើរូបថតវិញ គឺ រូបមុខព្រហ្មព្រាសាទបាយ័ន

www.yerngshare.blogspot.com

(មើលឃើញជិត) រូបអង្គរវត្ត (ឃើញពីចម្ងាយ) ហើយនិងមានព្រះសង្ឃពីរអង្គ គង់នៅទីនោះផង... ។

ក្របស្បៃវែកៅថ្មី ដែលប្រើដោយរូបថតនេះ មានលំនាំប្រហាក់ប្រហែលគ្នានឹងក្របចាស់ ដែលប្រើដោយគំនូរលាបពណ៌នោះដែរ ។

ក្រៅពីនោះ ខ្ញុំបាទក៏បានកែសំរួលពាក្យ និង ឃ្លាប្រយោគបន្តិចបន្តួចផងដែរ ដូចជា : ត្រង់ទំព័រទី ៩ បន្ទាត់ទី ៦ និង ទី ៧ កែថា :

- រៀបរាប់ពីការប្រកាប់ប្រចាក់គ្នា របស់ពួកពុករលួយ ពាលាអាវ៉ាសៃ ស៊ីសំណូក សូកប៉ាន់ ក្នុងគ្រប់ជំនាន់ ។

ត្រង់ទំព័រទី ១៩ បន្ទាត់ទី ៣ កែថា :

- រហូតមកដល់ចុងសតវត្សរ៍ទី ៦... ដើមសម័យចេនឡា...

ត្រង់ ទំព័រទី ៣៥ បន្ទាត់ ទី ២ ទី ៣ ទី ៤ កែថា :

- ម្នុសក្នុងលោកា រាល់រូបអាត្មា ស្អប់ខ្ពើមលាមក
តែតាមការពិត ជីវិតគំរក់ ស្អាយថង់លាមក
វីវក់សព្វឋាន ។

និងត្រង់ទំព័រ ទី ៥៣ បន្ទាត់ទី ៥ កែថា :

- បក ចោស បបេះ ចោចបាចបា...

www.yerngshare.blogspot.com

និងបន្ទាត់ទី ៥ កែថា :

- បូតបេះ បានបា ចោកបែនបុក...

ដូច្នេះ សូមប្រិយមិត្តអ្នកអានទាំងអស់ មេត្តាជ្រាបជាពតិមាន ។

សូមថ្លែងអំណរគុណជាពន្លឺក និង សូមជូនពរប្រិយមិត្តអ្នកអាន បានសមប្រកបតែនិងសេចក្តីសុខគ្រប់ប្រការ ។

១០/០១/២០០១

អ្នករឿបរឿង

www.yerngshare.blogspot.com

ទាចារអ្នកនិពន្ធ

ប្រិយមិត្តអ្នកអានជាទីគោរព !

សៀវភៅដែលមិត្តកំពុងកាន់នៅដៃនេះ មិនមែនជាកម្រងកំណាព្យ សំរាំងជ្រើសរើស ឬ អត្ថបទកំណាព្យល្អ ។ ប្រណីតនោះទេ ប៉ុន្តែ វាជាការចូកសរុបរបៀបសរសេរកាព្យខ្មែរយ៉ាងសំបូរបែបដែលជា សំណល់នៃគំនិតច្នៃប្រឌិតរបស់បុព្វបុរស ដូនតាយើង ដែលយើងទាំងអស់គ្នា គួរតែសិក្សានិងថែរក្សាខុស ។

ម៉្យាងដោយយោលទៅលើគំនិត ៖ បំណាច់កើតជាកូនខ្មែរ បើមិនបានធ្វើអ្វីឲ្យប្រសើរខ្ពង់ខ្ពស់ជូនប្រទេសជាតិមាតុភូមិទេ ត្រូវ កុំបំផ្លាញ ៖ ទើបខ្ញុំដែលមានសមត្ថភាពយល់ដឹងស្តួចស្តើង ប្រឹង រំលឹកការចេះចាំបន្តិចបន្តួច និង ប្រឹងប្រមូលឯកសារជំទាត់ខ្សោយ បំផុត ដែលសល់ពីការបំផ្លាញរបស់របបប្រល័យពូជសាសន៍ ប៉ុល ពត អៀង សារី មកចងក្រងជាកូនសៀវភៅនេះឡើង ដើម្បីជា កិច្ចតបស្នងសងគុណចំពោះបក្ស ណាសិរ្ស វីរៈយុទ្ធជន យុទ្ធនារី ដែលបានសង្គ្រោះជាតិ និង យើងទាំងអស់គ្នាឲ្យរស់រាន និង ដើម្បីជាសក្ខីភាពនៃការឈឺចាប់ និង ការនឹករលឹករបស់ខ្ញុំចំពោះ វិញ្ញាណក្ខន្ធ ទឹកភ្នែក និងឈាមរបស់ញាតិសាលោហិតកម្ពុជា ទាំងប៉ុន្មានរាប់ដែលបានណាចាកលោកនេះ ដោយបង្ខំ ក្នុងគ្រា

www.yerngshare.blogspot.com

ខ្ញុំចង់ផ្សាជាទីបំផុតក្រោមខម្ងួនព្រនង់ ដំបង ស្បង់ចប និងឆ្នាំ
ទណារ ជាងគ្មានដំកាចសាហាវរបស់ចនប្រល័យពូជសាសន៍ ...

សូមឲ្យវិញ្ញាណក្ខន្ធបងប្អូនទាំងអស់កក់ក្តៅនិងស្ងប់រំងាប់.. ។

ប្រិយមិត្តអ្នកអានជាទីស្នេហា !

ខ្ញុំជឿជាក់ថា ការសិក្សារបស់ខ្ញុំនេះ ប្រាកដជានៅខ្វះខាតច្រើន
ទាំងបរិមាណ និង ទាំងគុណភាព ។

សូមមិត្តទាំងអស់ ដែលជាអ្នកស្នេហាវប្បធម៌ជាតិ អក្សរ
សាស្ត្រ និងសិល្បៈជាតិ កុំមើលងាយទិតទំសិក្សាបន្ថែម រួចជួយ
វិភាគលំអឲ្យកាន់តែល្អ ប្រសើរឡើង ។

អ្នករៀបរៀង

www.yerngshare.blogspot.com

សូមឧទ្ទិសស្នាដៃនេះ

ជូនចំពោះ

បុព្វបុរសស្មៅហាដាតិ អស់លោកអ្នកប្រាជ្ញ តន្ត្រីបណ្ឌិត ដែលបានបន្តើក អក្សរសាស្ត្រជាតិ និងបានប្រយុទ្ធ តស៊ូពុះពារគ្រប់ខបសត្ត តួចគ្រប់ការលសម័យ ដើម្បីដែរក្បាកការពារអក្សរសាស្ត្រជាតិ ឱ្យគង់ខង់ហូតដល់ សព្វថ្ងៃនេះ ។

ដល់គុណបុត្រ គុណធីតា តម្កូវគ្រប់រូប និងគ្រប់ជំនាន់ដែលស្មៅហា អក្សរសាស្ត្រជាតិ . . . ខំសិក្សា និងខំជម្រុញឱ្យអក្សរសាស្ត្រ និងប្រពៃណីជាតិរីកចំរើន ។

អ្នករៀបរៀង

www.yerngshare.blogspot.com

មាតិកា

ទំព័រ

-ប្រវត្តិកំណាព្យខ្មែរ.....១៨

-បទមេបួន.....៣០

-បទបថ្យាវត្ត.....៣២

-បទកាកគតិ.....៣៤

-បទព្រហ្មគីតិ.....៣៦

-បទពំនោល.....៣៨

-បទបន្ទោលកាក.....៤០

-បទភុជង្គលីលា.....៤២

-បទពាក្យ ៦.....៤៤

-បទកង្កែបលោតលើគោក.....៤៦

-បទពាក្យ ៧.....៤៨

- បទវិធមាលី.....៥០

-បទអក្សរលួន.....៥២

-បទសត្វកាងស្លាប.....៥៤

www.yerngshare.blogspot.com

-បទនមោ.....៥៦
-បទ ក ខ ៥៨
-បទគោព័ទ្ធស្នឹង.....៦០
-បទអើយវ៉ា.....៦២
-បទក្របចក្រវាឡ.....៦៤
-បទម្កុរខ្លាក់កែវ.....៦៦
-បទនាគក្បៀវក្រវ៉ាត់.....៦៨
-បទកង្កែបលោតកណ្តាលស្រះ.....៧០
-បទយត្តិភ័ង្គ.....៧២
-បទពស់លេបកន្ទុយ.....៧៤
-បទថយក្រោយចូលព្រៃក.....៧៦
-បទសុក្រទិនវិសាល.....៧៨
-បទសោរទិនវិសាល.....៨០
-បទពាក្យ ៨.....៨២
-បទពាក្យ ៨ (បន្ទាប់បទពាក្យ ៨ ធម្មតា).....៨៤
-បទត្រីពិធព័ន្ធ (សុតន្តប្រីជាឥន្ទ)....៨៦
www.yerngshare.blogspot.com

-បទត្រីពិធព័ន្ធ (អៀង សាយ)..... ៨៨
-បទអក្សរសង្វាស..... ៩០
-បទរមាំងដើរព្រៃ..... ៩២
-បទឆ័ត្របីជាន់..... ៩៤
-បទនាគរាជប្លែងឫទ្ធ..... ៩៦
-បទនាគបរិព័ន្ធ..... ៩៨
-បទពាក្យ ៩ ..... ១០០
-បទជាប់ទង..... ១០២
-បទសីង្ហតោលេងកន្ទុយ..... ១០៤
-បទកង្កែបលោតស្លាក់ពេជ្រ..... ១០៦
-បទរលកខ្ទប់ច្រាំង..... ១០៨
-បទសឡាបលូន..... ១១០
-បទព្រះចន្ទ្រចាំងឆ័ត្រ..... ១១២
-បទសារថីទាញរថ..... ១១៤
-បទកង្កែបលោតផ្ចាត់ខ្ចៅ..... ១១៦
-បទផ្កាឈូកវីក..... ១១៨
-បទរលកសមុទ្រ..... ១២០
www.yerngshare.blogspot.com

-បទពាក្យ ១០.....១២២
-បទសបាត់សប៊ីង.....១២៤
-បទវង្សវិចិត្រ.....១២៦
-បទត្រឡាចឡើងទ្រើង.....១២៨
-បទពាក្យ ១១.....១៣១
-បទសហរា.....១៣៣

www.yerngshare.blogspot.com

ព្យញ្ជនៈខ្មែរ

ក ខ គ ឃ ង ច ឆ ជ ឈ ញ
ដ ឋ ឌ ឍ ណ ត ថ ទ ធ ន
ប ផ ព ភ ម យ រ ល វ ស
ហ ឡ អ ។

ស្រៈនិស្ស័យ

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ
ែ ៃ ោ ៅ ំ ះ ។

ស្រៈពេញត្ន

ឣ ឤ ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ
ឱ ឲ ឳ ឴ ឵ ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ំ ះ ៈ

www.yerngshare.blogspot.com

ដូចម្តេចដែលហៅថាកំណាព្យ ?

សាកល្បងឆ្លើយ :

កំណាព្យគឺជាកម្រងពាក្យសំដី ដែលមានការចាប់ចុងចួន តិរោះរណ្តំណែងណង មានឃ្លា មានល្បះ និង មានកំរិតចំនួនត្បាង្គជាកំណត់ . . . ចេញពីទឹកចិត្តរំភើប និង ធ្វើឲ្យអ្នកជងរំភើបជាមួយ ។

ឧទាហរណ៍ :

កាច់ធ្នុងច្រកស្មុក

ដើរចូលក្នុងស្រុក ធ្វើឫកអាចារ្យ ភូតភរប្រជា
ចានច្រើនកាលណា ពាក់ធ្នុងសង្ហារ សាហាវលើសដើម ។

ខ្មែរអើយរឿងពិត

ខ្មែរតោងពិនិត្យ គិតគ្រប់ផង្គើម ខ្មែរបីលានថ្ងៃយ
ស្វាប់ឈាមសើម ។ កុំភ្លេចរឿងដើម ស្នាដៃ ប៉ុលពត ។

កំណាព្យកាព្យឃ្លោង ?

ពាក្យកំណាព្យកាព្យឃ្លោងនេះ ដូនតាយើងប្រើសំគាល់ ឬចង្អុលបង្ហាញពីលក្ខណៈដ៏ល្អរបស់កំណាព្យខ្មែរ ដែលចេញពីទឹកដៃ ដ៏ប៉ិនប្រសប់របស់កវី គឺថាកំណាព្យនោះទាំងរូបភាព ទាំងខ្លឹមសារ មានសម្ផស្ស និង សោភ័ណ រណ្តំបត់បែន ឃ្លោងបញ្ជិតបញ្ជៀង មិនត្រង់ស្តូក ប៉ុន្តែមានន័យគ្រប់គ្រាន់ ។

www.yerngshare.blogspot.com

ឧទាហរណ៍ :

- សូរិយាល្ងាចថ្ងៃ សូរិយាល្ងាចថ្ងៃ ទន្សោងគោព្រៃ រកស៊ីជើងភ្នំ ។
- ស៊ីតួចដោយតួច ស៊ីធំដោយធំ រកស៊ីជើងភ្នំ ធីកទឹកដងអូរ។
- ស៊ីធីកអូចហើយ ប្រជល់គ្នាវរ សុទ្ធតែឡើងក អួតអាងកម្ងែង។

តួយ៉ាងដូចអត្ថបទកំណាព្យជាឧទាហរណ៍ខាងលើនេះមានន័យពីរ៖

១ - ន័យត្រង់ : និយាយពីសកម្មភាព ប្រចាំថ្ងៃរបស់ទន្សោងគោព្រៃ

២ ន័យបញ្ជិតបញ្ជៀង : រៀបរាប់ពីការប្រកាប់ប្រចាក់គ្នា របស់ពួកពុករលួយពាលាអារ៉ាំសែ ស៊ីសំណូក សូកប៉ាន់ក្នុងគ្រប់ជំនាន់ ។

ហេតុហ្នឹងហើយ ទើបដូនតាយើង និយមប្រើពាក្យថា តំណាព្យ ការព្យឃ្លោងយ៉ាងដូចនេះ ។

តើកំណាព្យ និង កម្រងតែវខុសគ្នាយ៉ាងណា ?

សាកល្បងធ្វើយ ៖

កម្រងតែវ គឺជាកម្រងពាក្យសំដី ដែលមានការចាប់ចុងចួនខាក់ទងគ្នារោះរណ្តំណែងណងដែរ ប៉ុន្តែមិនមានកំរិតឃ្លោ ឬ ល្បះ ឬ ឥតចំនួនព្យាង្គជាកំណត់ទេ ។

ឧទាហរណ៍

ក្រុងទស្សមុខមារស្ទើរវង្សពង្សក្រឡាអស្តារប្រទំត្រាស់ថា អើបុញ្ញ

www.yerngshare.blogspot.com

កាយក្នុយមារវើយចូរនោងត្រាណាប្រែក្រឡា ជាសាកសពសីតា
អណ្តែតទឹក ទេវឯប៉ាន ជាស្វីមនុស្សាជាការធាប់ចុះណា បុញ្ញកាយ
ក្នុយមា . . . ។

(ពោលស្បែកធំ : រឿងរាមកេរ្តិ៍)

ធាតុកំណាព្យ

នៅក្នុងកំណាព្យ មានធាតុសំខាន់ ៗ ដូចតទៅនេះ ៖

- ព្យាង្គ
- ឃ្លា
- ល្បះឬល្បះទ័ណ្ឌ

ព្យាង្គ : សំឡេងមួយម៉ាត់ ៗ នៅក្នុងកំណាព្យហៅថាព្យាង្គ ។

ឃ្លា : ព្យាង្គច្រើនរួមគ្នា បានជាឃ្លា ។

ល្បះ : ឃ្លាច្រើនរួមគ្នាមក ដោយមានទ័ណ្ឌ ហៅថាល្បះ ឬ
ល្បះទ័ណ្ឌ ។

ព្យាង្គ ឃ្លា

1234 1234 1234 1234 ។

ល្បះ

www.yerngshare.blogspot.com

ព្យាង្គ និង ពាក្យ

សូមកុំច្រឡំ ព្យាង្គ និង ពាក្យ

ព្យាង្គ : ព្យាង្គគឺសំឡេងចេញមកម្តង ទោះបានន័យក្តី មិនបានន័យក្តីហៅថាព្យាង្គ ។

ឧទាហរណ៍ : ក - គ - គិ កិ - បង - សុំ - ទៅ - ធាន់ - ទ្ធ -
(។ ល ។ និង ។ ល ។)

ពាក្យ : ពាក្យគឺសំឡេងចេញមកម្តងក្តី ឬ ច្រើនដងក្តី មានន័យគ្រប់គ្រាន់ហៅថាពាក្យ ។

ឧទាហរណ៍ :

- ពាក្យ ១ ព្យាង្គ : ក . ខ . ឈប់ . គិត . ពេញ
(។ល។ និង ។ល។)
- ពាក្យ ២ ព្យាង្គ : សំដី . សម្រស់ . ប្រសាសន៍ . សម្បត្តិ
(។ល។ និង ។ល។)
- ពាក្យ ៣ ព្យាង្គ : អន្តរាធាន . វិនិច្ឆ័យ . កេងប្រវ័ញ្ច
(។ល។និង ។ល។)
- ពាក្យ ៤ ព្យាង្គ : មមើមមាយ - អស្ចារ្យអស្ចាន
ធពណ្ណារឿ (។ល។ និង ។ល។)

នៅក្នុងកំណាព្យគេចែកពាក្យជាពីរគឺ { ពាក្យពេចន៍ / ពាក្យសម្ផស្ស

www.yerngshare.blogspot.com

១- ពាក្យពេចន៍ : គឺជាសំរាប់រំលេចន័យទ្វីមសារ របស់អត្ថបទ កំណាព្យឬលេចធ្លោឡើង ឬអត្ថបទនោះមានសោភ័ណខ្ពស់ ពោលគឺបង្កើតរូបារម្មណ៍ និង បំផុសឬដឹងច្បាស់ពីគំនិតរបស់ អត្ថបទ ចង់និយាយយ៉ាងណាៗ នោះ ។

២- ពាក្យសម្ផស្ស : គឺជាពាក្យគន្លឹះចួន ឬ ហៅចំណាប់ចុងចួន ដែលធ្វើឬរូបភាពឬ ទម្រង់នៃអត្ថបទកំណាព្យមានសម្រស់ល្អឡើង ប្រកបដោយលក្ខណៈ ចួនជួនណ្តាំ ។

គេចែកពាក្យសម្ផស្សជាពីរគឺ { ក - ពាក្យសម្ផស្សក្នុង
ខ - ពាក្យសម្ផស្សក្រៅ

ក- ពាក្យសម្ផស្សក្នុង :គឺសំគាល់លើចំណាប់ចួន ជួនណ្តាំ ដែលស្ថិតក្នុងឃ្លាជាមួយគ្នា ។

ឧទាហរណ៍ : ស្រីប្តីពីរបីពុំគាប់រាប់ -
ស្រី ចួន និង ប្តី
គាប់ ចួន និង រាប់

នៅក្នុងឃ្លាតែមួយយ៉ាងនោះហៅថា សម្ផស្សក្នុង ។

ខ- ពាក្យសម្ផស្សក្រៅ : គឺសំគាល់ចំណាប់ចួន ជួនណ្តាំដែលឆ្លងគ្នាពីឃ្លាមួយទៅឃ្លាមួយទៀត ឬពីល្បះមួយទៅល្បះមួយទៀត ។

ឧទាហរណ៍ :

- សូរិយាកើតឃ្លង់ ក្នុងមុងចំបែង លោកខែកើតស្រែង

www.yerngshare.blogspot.com

ផ្តាយដុះកន្ទុយ ។

- មូសពាំរ៉ី ពីព្រៃធ្វើទុយ ខ្លាចាស់ពោះស្ងួយ
ស៊ីទុយធីនមូស ។

- រុយជាប់ពីងពាង ទៅឈើមាត់ឈ្លស បានដៃសត្វមូស
បីតឈាមសព្វសត្វ ។

(កំណាព្យនេះសរសេរក្នុងសម័យ លន់ នុល បកគាក្រាត
ពីរបបជិះជាន់ពុករលួយដល់ខ្លួនធ្លឹង ចៃអាមេរិកកាង ។)

សូរស័ព្ទ ឬ សូរសៀង ឬ សំនៀង

សូរស័ព្ទ សូរសៀង ឬ សំនៀងនេះ ទៅក្នុងកំណាព្យមាន
សារៈសំខាន់ណាស់ ព្រោះកំណាព្យដែលល្អ គឺកំណាព្យដែលមាន
ចំណាប់ចូន និង ផ្ទួនមានសូរសំឡេងដូចគ្នា ។ ពោលបើសំនៀង
នោះ ចេញមកពីព្យញ្ជនៈឃោសៈ ខ្យល់គ្រលរសំឡេង "អ៊" ត្រូវ
តែឮចូនឃោសៈដែរ ។

ដូចពាក្យ : គិត. មិត្ត. ពិត. រឹត.
គុំ · ជុំ - ធំ . ធំ - ។ល។ និង ។ល។

បើសំនៀងចេញមកពីព្យញ្ជនៈ អឃោសៈ សំឡេងតូចស្រួយ
ខ្យល់ «អ» ត្រូវតែឮចូនអឃោសៈដែរ ។

ដូចពាក្យ : កង . បង . ឡង . សង . ផង .

www.yerngshare.blogspot.com

សត្វ· ចាត់. កាត់- ម៉ាត់- (ឃលៗនិងៗលៗ)

មិនត្រូវយកយោស: ទៅចួននឹងអយោស: ក៏ប៉ុន្តែតាមការសង្កេត
ចេញឲ្យឆ្គងឬភាក្យទាំងឡាយណា ដែលប្រើស្រៈ " ួ " ស្រៈ " ឿ "
និងស្រៈ " ឿ " នោះឲ្យញែកយោស: និង អយោស:អាចចួនគ្នា
បាន ព្រោះមានសូរសំឡេងដូចគ្នា ។

ឧទាហរណ៍ " ស្រៈ " ួ " គួ . តួ

គួន. ចួន

ពួន. ខ្លួន (ឃលៗ និង ៗលៗ)

ស្រៈ " ឿ " លឿង. សឿង

គ្រឿង ក្បឿង(ឃលៗនិងៗលៗ)

ស្រៈ " ឿ " ទិតៀន បៀតបៀន

ខៀត ស្តៀត (ឃលៗនិងៗលៗ)

ឬអាចឆ្ងងគ្នាបែបនេះ កំបានគឺ យោស:ស្រៈ " អា " ចួននឹង
អយោស: ស្រៈ " អៀ "

ដូចភាក្យ ឃ្លាន ខៀន

នាង សៀង

វាត បៀត (ឃលៗ និង ៗ ល ៗ)

អាចនៅមានគ្រាន់តែនេះខ្លះទៀត ប៉ុន្តែជាសំខាន់ចំណាំតែ សូរ
សំឡេងដូចគ្នា ។

www.yerngshare.blogspot.com

វង្វាស់ពាក្យ ឬ មាត្រាពាក្យ

- វង្វាស់ពាក្យ ឬ មាត្រាពាក្យ គឺចំនួនព្យាង្គ ដាកំណត់ក្នុងឃ្លាឱមួយ ។ និង ចំនួនឃ្លា ដាកំណត់ក្នុងល្បះនីមួយ ។ ។ គឺអាស្រ័យចំណាច់ចួនខុសគ្នា . . . កំណត់ព្យាង្គនិង ឃ្លា ក្នុងល្បះខុស ។ គ្នានេះហើយ ដែលនាំឲ្យ រូបភាព " ខម្រង់ " កំណាព្យខំងែឡាយខុសគ្នា និងមានឈ្មោះកំប្លែក ។ គ្នាដែរ ។

ឧទាហរណ៍ : បទមេបួន

មួយល្បះមាន ៤ ឃ្លា ក្នុងមួយឃ្លាមាន ៤ ព្យាង្គ ។

" 4. 4. 4. 4. ។ "

- បទភាគតិ

មួយល្បះមាន៧ឃ្លា ក្នុងមួយឃ្លាមាន ៤ ព្យាង្គស្មើគ្នា ។

" 4. 4. 4. 4. 4. 4. 4. ។ " (។ល។ និង ។ល។)

ចង្វាក់

ពាក្យចង្វាក់នៅក្នុងកំណាព្យគឺ សំគាល់ការរលឹក ឬ ដាក់សំឡេងដែលមានលក្ខណៈខុស ។ គ្នា នៅតាមបទកំណាព្យនីមួយ ។ ។ វាជាជំនួយជួយសំរួលដល់ការនិពន្ធ ការពោល ឬ កំការសូត្រកំណាព្យ និង ជួយជម្រុញឲ្យកំណាព្យមានលក្ខណៈពិរោះរណ្តំជាតន្ត្រី ។

www.yerngshare.blogspot.com

ឧទាហរណ៍ : បទភាសា ៧

ត្រូវសង្កត់សំឡេងលើព្យាង្គ 2 និង 4

- ស្តាយសាច់ ស្រអែម តែមសំដី ...

បទភាសា ៨

- ត្រូវសង្កត់សំឡេងលើព្យាង្គ 3 និង 5

- អនិច្ចា តោថ្ម លោភកសាង ... (ឯឯ និង ឯឯ)

សង្កេត

១ - បទភាសា ៦ ភាសា៧ ភាសា៨ ភាសា៩ ភាសា១០ និងភាសា ១១ ជាឈ្មោះកំណាព្យ ដែលចាស់បុរាណយើងបានឧទ្ទិយមកប្រើ ប៉ុន្តែតាមការពិត " ភាសា " នេះមិនមែនសំគាល់ចំនួនភាសានៅក្នុងឃ្លាទេ ផ្ទុយទៅវិញ គឺសំគាល់ចំនួនព្យាង្គ នៅក្នុងឃ្លានីមួយៗ ពោលគឺ :បទភាសា ៦ មាន ៦ ព្យាង្គក្នុងមួយឃ្លា - បទភាសា៧ មាន ៧ ព្យាង្គ ក្នុងមួយឃ្លា - បទភាសា ៨ មាន ៨ ព្យាង្គក្នុងមួយឃ្លា បទភាសា ៩ មាន ៩ ព្យាង្គ ក្នុងមួយឃ្លា - បទភាសា ១០ មាន ១០ ព្យាង្គក្នុងមួយឃ្លា និង បទភាសា ១១ មាន ១១ព្យាង្គក្នុងមួយឃ្លា ។

២ - តាមធម្មតាបើគេនិពន្ធអត្ថបទកំណាព្យមួយដែលមាន ច្រើនឈ្នះ គេត្រូវរក្សាចំណាប់ជួន តាំងពីឈ្នះទី១រហូតដល់ឈ្នះបញ្ចប់ ... មិនត្រូវឲ្យក្លាត់ ឬ កំជាប់ជួន នៅដំណាក់ណាមួយឡើយ ។

www.yerngshare.blogspot.com

៣ - ក្រោយពីការសិក្សារបៀបសូត្រកំណាព្យខ្មែរ យើងអាច
សង្កេតឃើញថា: បទកំណាព្យនីមួយៗមិនមែនសម្រាប់បំពេញតែមនោ
សញ្ចេតនាមួយប៉ុណ្ណោះទេ ផ្ទុយទៅវិញបទទាំងនោះ អាចបំពេញ
ឱ្យវែតគ្រប់មនោសញ្ចេតនារបស់មនុស្ស ដូចជារំតើបសប្បាយ
តំសន់ ពិពណ៌នា ទំនុកក្រាត់ក្រាស កំហឹងខ្លួនប្រឿនប្រដៅ
សង្វេគអង្វរ ។ល។ និង ។ល។
ដាក់ស្មើនគ្រាន់តែបទភាគតិមួយ យើងអាចសូត្របាន៤បែបគឺ:

- សូត្របែបភូនក្មេង
- សូត្របែបចាស់
- សូត្របែបក្អែកលោត
- សូត្របែបក្អែកបូល
- សូត្របែបពិពណ៌នា
- សូត្របែបចំនួន៣
- សូត្របែបតិលាប
- សូត្របែបភាគភាត់ត្រើយ
- សូត្របែបគ្រលួកូណាដាដើមដែលអាស្រ័យដោយខ្លឹមសារ

និងមនោសញ្ចេតនានៃអត្ថបទនោះកំណត់ ។

www.yerngshare.blogspot.com

សាកល្បងស្រាវជ្រាវ :

ប្រវត្តិភំណាព្យខ្មែរ

- បើយើងពិនិត្យកន្លែងលើបទភ្លេង និង ចំនុចប្រៀង នៃវង់ភ្លេងអារក្សវែងក្រុម អ្នកស្រាវជ្រាវតន្ត្រីខ្មែរយល់ថា ជាវង់ភ្លេងទៀតដែលកើតមុនគេ ដូចគ្នានឹងគ្រឿង ជំគងតាបក្របីរបស់បងប្អូនជនជាតិ ដែរនោះ ជាតន្ត្រីសំរាប់បំរើពិធីផ្សេងៗ ។ ឬជា អារក្សអ្នកតា ដែលជាជំនឿរបស់ខ្មែរដើម ហើយដែលកើតមានតាំងពីមុនសម័យដែលព្រះពុទ្ធសាសនា និង ព្រាហ្មញ្ញសាសនា រហូតចូលមកកម្ពុជា " ៣០៩ ឆ្នាំ មុន គ . ស " (១) នេះ . . .

- ម៉្យាងទៀត បើយើងពិនិត្យកន្លែងលើចំនុចប្រៀង បទភ្លេង នៃវង់ភ្លេងប្រពៃណី (ភ្លេងការ) ដែលក្រុមអ្នកស្រាវជ្រាវយល់ថាកើតមានតាំងពីសតវត្សទី ១ នៃគ្រីស្តសករាជ គឺក្នុងពេលដែលរៀបអាពាហ៍ពិពាហ៍ មង្គលការព្រះថោងនិងនាងនាគ (ហ៊ុនទៀន និងនាងលីវយី ឬ ព្រះនាងសោមាក្នុងព្រះច័ន្ទ) ហើយដែលមានបទមួយចំនួនទាក់ទងនឹងប្រវត្តិសាស្ត្រ ដូចជាបទ ព្រះថោងនាងនាគនាគព័ន្ធ ជាដើម (១ ល ៗ និង ១ ល ១) យើងឃើញថាកំណាព្យខ្លះដែលកើតមានមុនគេ គឺបទមេបួន ដែលក្នុងមួយឃ្លះ

---

(១) ប្រវត្តិពុទ្ធសាសនាប្រៃទេសខ្មែរ ជាំង ខាត់

www.yerngshare.blogspot.com

ទំណួមាន ៤ ឃ្លា និង ក្នុងមួយឃ្លាមាន ៤ ព្យាង្គ ស្មើគ្នា ។
" 4. 4. 4. 4. ។ "

រហូតមកដល់ចុងសតវត្សទី៦ ដើមសម័យចេនឡា ទើបយើងឃើញមាន៤ទម្រង់កំណាព្យមួយបទទៀតកើតឡើងឈ្មោះបទឧបជាតិក្នុងមួយ ឈ្នះមាន ៤ ឃ្លា និងក្នុងមួយឃ្លា មាន ៨ ព្យាង្គ . . . ប៉ុន្តែការចាប់ចុងចួន មិនដូចបទភាក្យ ៨ ដែលកើតសម័យក្រោយទេ ។ " 8. 8. 8. 8. ។ "

នៅក្នុងរឿងរាមកេរ្តិ៍ តាំងពី ១ ដល់ពី ១០ ដែលកើតមាននៅសម័យអង្គរ គេឃើញមានទម្រង់កំណាព្យ ៥ បទទៀត កើតឡើងគឺ ៖

បទភាកតតិ : ដែលក្នុងមួយឈ្នះទំណួមាន ៧ ឃ្លា និងក្នុងមួយឃ្លាមាន ៤ ព្យាង្គស្មើគ្នា ។

" 4. 4. 4. 4. 4. 4. 4. ។ "

បទព្រហ្មគីតិ : មួយឈ្នះមាន ៤ ឃ្លា - ឃ្លាទី ១ មាន ៥ ព្យាង្គ ឃ្លាទី ២ មាន ៦ ព្យាង្គ ឃ្លាទី ៣ មាន ៥ ព្យាង្គ និង ឃ្លាទី ៤ មាន ៦ ព្យាង្គ ។ " 5. 6. 5. 6. ។ "

បទតំនោល : មួយឈ្នះមាន ពីរ ឃ្លា : ឃ្លាទី ១ មាន ៦ ព្យាង្គ ឃ្លាទី ២ មាន ៤ ព្យាង្គ និង ឃ្លាទី ៣ មាន ៦ ព្យាង្គ ។ " 6. 4. 6. ។ "

បទបន្ទាលតាក : មួយឈ្នះមាន ៤ ឃ្លា : ឃ្លាទី ១ មាន ៤ ព្យាង្គ

www.yerngshare.blogspot.com

ឃ្លាទី ២ មាន ៦ ព្យាង្គ ឃ្លាទី ៣ មាន ៤ ព្យាង្គ ឃ្លាទី ៤ មាន ៦ ព្យាង្គ ។ " 4. 6. 4. 6. ។ "

ចតុកុដង្គលីលា : មួយល្បះមាន ៣ឃ្លា : ឃ្លាទី ១ មាន ៦ ព្យាង្គ, ឃ្លាទី ២ និងទី ៣ មាន ៤ ព្យាង្គ " 6. 4. 4. ។

ទម្រង់កំណាព្យទាំង ៥ ខាងលើ មានតាំងពីសម័យអង្គរមក ម្ល៉េះ ប៉ុន្តែគេពុំទាន់ឃើញប្រើឈ្មោះនៅឡើយ ។ រហូតមកដល់ សតវត្សទី ១៥ ឆ្នាំ " ១៦៤៨ " ក្នុងលើកអង្គរវត្ត-អ្នកចាំង ទើបកំណាព្យដែលនេះមានប្រើឈ្មោះ ជា កាកគតិ ព្រលឹតិតំនោលបន្ទោលកាក និង កុដង្គលីលា ។

- នៅក្នុងរឿងរាមកេរ្តិ៍ ពីខ្សែ ៣៥ ដល់ ៤០ ដែលជាស្នាដៃបន្ត ហើយដែលអ្នកស្រាវជ្រាវអក្សរសាស្ត្រជាតិយល់ថាជាស្នាដៃកើតក្រោយសម័យអង្គរ ឬក៏ក្រោយពេលច្រូលច្របល់ចលាចលគ្រោះសៀមលុកលុយក្រុងអង្គរនោះ គេឃើញមានកំណាព្យថ្មីមួយទៀត គឺបទពាក្យ ៦ ដែលក្នុងមួយល្បះមាន ៤ ឃ្លា ក្នុងមួយឃ្លាមាន ៦ព្យាង្គ ស្មើគ្នា " 6. 6. 6. 6. ។ "

- មកដល់សម័យចតុមុខ ចាប់ពីពេលដែលព្រះបរមរាជាយ៉ាតប្តូររាជធានីពីអង្គរមកតតាំងនៅស្រីសន្ធរ រួចមកភ្នំពេញនិងការផ្ទាស់ប្តូរទីក្រុងចុះឡើង ពីភ្នំពេញទៅលង្វែក ពីលង្វែកទៅឧត្តុង្គនិងកន្លែងដទៃជាច្រើនទៀត រហូតដល់សម័យនរោត្តមប្តូរទីក្រុងពីឧត្តុង្គមក

www.yerngshare.blogspot.com

ភ្នំពេញ . . ដល់សព្វថ្ងៃនេះ គេឃើញមានកំណាព្យជារាប់ច្រើនទៀត
បានកើតឡើង ។

បទភាសា ៧ : ក្នុងមួយល្បះមាន ៤ ឃ្លាក្នុងមួយឃ្លាមាន
៧ព្យាង្គ " 7. 7. 7. 7. ។ "

បទភាសា ៨ : ក្នុងមួយល្បះមាន ៤ ឃ្លាក្នុងមួយឃ្លាមាន
៨ ព្យាង្គ " 8. 8. 8. 8. ។ "

បទភាសា ៩ : ក្នុងមួយល្បះមាន ៤ ឃ្លាក្នុងមួយឃ្លាមាន
៩ ព្យាង្គ " 9. 9. 9. 9. ។ "

បទភាសា ១០ : ក្នុងមួយល្បះមាន ៤ ឃ្លា ក្នុងមួយឃ្លាមាន
១០ ព្យាង្គ " 10. 10. 10. 10. ។ "

បទភាសា ១១ : ក្នុងមួយល្បះមាន ៤ ឃ្លា ក្នុងមួយឃ្លាមាន
១១ ព្យាង្គ " 11. 11. 11 . 11 . ។ "

- ហើយមានបទច្រើនទៀតដែលជារបៀបសរសេរបំភ្លៃចេញ
ពីបទខាងលើយ៉ាងខាងក្រោយនេះ ដូចជា ៖ បទ ន មោ -
បទ ក ខ បទអក្សរលួន - បទអក្សរសង្វាស បទកង្កែបលោត
កណ្តាលស្រះ បទកង្កែបលោតលើគោក - បទកង្កែបលោតស្ទាក់
ពេជ្រ - បទកង្កែបលោតផ្តាត់ខ្នៅ - បទនាគបរិព័ទ្ធ - បទនាគគៀវក្រវាត់
បទនាគរាជម្ចែងឫទ្ធ - បទគោព័ទ្ធស្ទឹង - បទសីង្ហតោលេង
តន្ទុយ - បទមេរាំដើរព្រៃ . បទផ្កាឈូកវីក - បទក្របចក្រវាឡ

www.yerngshare.blogspot.com

បទម្ភរខ្លាក់កែវ - បទធ័ត្រមីដាន - បទលេកយោលយាវ
បទលេកខ្លួបត្រាំង - បទសហារ - បទវិធមាលី បទតស់លេប
កន្ទុយ-បទថយក្រោយចូលព្រៃក បទសត្វកាងស្វាប បទមាំង
បើកចាស-បទទន្សាយទីសទាស-បទមាន់ទីកបណ្តើរកូន-បទសារ
ជិទាញ-បទអើយរ៉ា-បទត្រឡាចឡើងទ្រើង-បទសុក្រទិនវិសាល
បទសោរទិនវិសាល-បទយត្តិកង្គ-បទសចាត់សប៊ីង-បទជាប់ទង
បទត្រីពិធព័ន្ធ-បទសង្ឃាបលួន-បទឆ្មារិចិត្រ និង ព្រះចន្ទ្រចាំងធ័ត្រ

សង្ខេប

មុនគេ : ១ - បទខេមួន

សម័យមុនអង្គរ : ២ - បទបថ្យាវត្ត

សម័យអង្គរ : ៣ - បទកាកគតិ

៤ - បទព្រហ្មគីតិ

៥ - បទពំនោល

៦ បទបន្ទោលកាក

៧ - បទភុជង្គលីលា

សម័យក្រោយអង្គរ : ៨ - បទពាក្យ ៦

សម័យចតុមុខ : ៩ - បទពាក្យ៧, ១០ បទពាក្យ៨,១១-
បទពាក្យ៩,១២-បទពាក្យ ១០,១៣

www.yerngshare.blogspot.com

បទពាក្យ ១១, ១៤- បទកាកគតិ ១, ១៥- បទនមោ
១៦- បទអក្សរលួន, ១៧- អក្សរសង្វាស, ១៨-
បទកង្កែបលោតកណ្តាលព្រះ, ១៩- កង្កែបលោត
លើគាក, ២០ កង្កែបលោតស្វាក់ពេជ្រ, ២១-
កង្កែបលោតផ្តាត់ខ្នោ, ២២- នាគបរិព័ន្ធ. ២៣-
គៀកក្រវាត់, ២៤ នាគរាជប្លែងឫទ្ធ; ២៥ គោព័ន្ធស្នឹង,
២៦- សីង្ហគោលេងកន្ទុយ, ២៧ រមាំងដើរព្រៃ, ២៨ ផ្កាឈូកវែក
២៩- ក្របក្រវាឡ, ៣០- ម្កាន់ធ្លាក់កែវ, ៣១- ធ័ត្របីជាន់.
៣២- រលកយោលយាវ. ៣៣- រលកខ្ទប់ច្រាំង, ៣៤ សហរា,
៣៥- វិវិធមាលី, ៣៦ ខ្សែលេបកន្ទុះ, ៣៧- សត្វកាង
ស្ទុប, ៣៨ ថយក្រោយចូលព្រៃក, ៣៩ រមាំងបើក,
ចាស, ៤០ ទន្សាយទឹសខ្មៅស, ៤១- ម៉ាន់ទឹកបណ្តើរកូន,
៤២- សារថីទាញរថ, ៤៣- អើយ៉ា, ៤៤ សុក្រទិដ្ឋវិសាល,
៤៥ សោរទិដ្ឋវិសាល; ៤៦- ត្រឡាចឡើងទ្រើង, ៤៧- យត្តិភ័ង្គ,
៤៨- ជាប់ខ្នង, ៤៩- សចាត់ស្ទុបឹង, ៥០- ត្រពិះព័ន្ធ,
៥១- សឡាបលួន, ៥២- វិស្សុកម្ម, ៥៣- ព្រះបន្ទូចាំងធ័ត្រ,

ចំនាត់ចំនងរវាងកំណាព្យ និង ទម្រង់សិល្បៈដទៃទៀត

បើយើងសង្កេតមើលស្នាដៃផ្នែក ក្សរសាស្ត្រ ដែលបុព្វបុរស ដូនតា
យើងបានបន្សល់ទុកដល់យើងសព្វថ្ងៃនេះ យើងនឹងឃើញភ្លាមថា

www.yerngshare.blogspot.com

ភាគច្រើនសុទ្ធតែជាកំណាព្យកាព្យឃ្លោង ដូចជាវៀង រាមកេរ្តិ៍ ចុំទាវ ទិព្វសង្វារ កាកី ច្បាប់ប្រុស ច្បាប់ស្រី ច្បាប់កេរ្តិ៍កាល ច្បាប់ក្រម លើកជុំចនិដ្ឋត្រី (។ល។ចនិដ្ឋ។ល។) នេះជាសក្ខីភាព បញ្ជាក់អំពីវិធីសាស្ត្រអប់រំបែបបុរាណរបស់ដូនតាយើង ដែលយក រូបភាពកំណាព្យ "តិរោះត្រចៀក" ជាមធ្យោបាយ ដើម្បីធ្វើឲ្យ ស្រួលបញ្ចូលទឹមសារនៃការអប់រំខ្លួនទៅដល់ឡាយ ដែលលោកចង់ បាន ឲ្យទៅដក់ជាប់ចាំជាប់ក្នុងសតិអារម្មណ៍ របស់កុលបុត្រ កុលធីតារបស់ខ្លួន ។

ទៅក្នុងសង្គមកម្ពុជាយើង កំណាព្យមានឥទ្ធិពលធំណាស់ ។ ក្រៅពីការរស់និងបំពេញតួនាទីដោយឯកឯង(ស្នូត្រឬស្នូត្រកំណាព្យ) កំណាព្យបានជះឥទ្ធិពល និង មានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ចំជុត ជាមួយនឹងទម្រង់សិល្បៈដទៃទៀតរបស់ខ្មែរយើងដូចជា : ភ្លេងអារក្ស ភ្លេងប្រពៃណី "ភ្លេងការ" រាំប្រពៃណីរាំបុរាណ ល្ខោនស្រមោល(ស្បែកធំ_ស្បែកតូច)ល្ខោនខោល(ល្ខោនពាក់មុខ) យីកេអាបៃ ល្ខោនមហោរី ល្ខោនចាសាក់ អាយ៉ៃ ចាប៉ី (។ល។ចនិដ្ឋ។ល។) ។

ទម្រង់សិល្បៈទាំងអស់នេះ ត្រូវការកំណាព្យជាចាំបាច់សម្រាប់ ជួយកំរិតទម្រង់ជួយលើកសម្ផស្ស និង សោភ័ណរបស់ខ្លួន ។

www.yerngshare.blogspot.com

តំណាឲ្យ

- ភ្លេងអារក្ស និង ភ្លេងការ
- រចាំប្រពៃណី
- រចាំបុរាណ
- ល្ខោនស្រមោល (ស្បែកធំ-តូច)
- ល្ខោនខោល (ល្ខោនតាក់មុខ)
- យីកេ
- ល្ខោនមហោរី
- ល្ខោនបាសាក់
- អាប៉េ
- អាយ៉ៃ
- ចាប៉ី (ឯលៗ និង ឯលៗ)

ចំពោះអ្នកសិក្សា ទម្រង់សិល្បៈខ្មែរវិញ កំណាឲ្យក៏ជាកត្តាមួយសំខាន់ក្នុងកត្តាច្រើនទៀត ដែលជួយបញ្ជាក់អំពីចំណាស់ និងទម្រង់សិល្បៈនីមួយៗ ។ ផ្ទុយទៅវិញទម្រង់សិល្បៈដទៃទៀតកំពុងជួបនូវឥទ្ធិពលជំនេងដែរសំរាប់បញ្ជាក់អំពីចំណាស់នៃកំណាឲ្យនីមួយៗរបស់ៈយើង ។ ដូច្នេះបើចង់សិក្សាកំណាឲ្យខ្មែរ គួរសិក្សាពីទម្រង់សិល្បៈខ្មែរដទៃទៀតផង ហើយបើចង់សិក្សាពីទម្រង់សិល្បៈដទៃទៀតក៏មិនអាចបោះបង់ចោលកំណាឲ្យបានដែរ ។

www.yerngshare.blogspot.com

សញ្ញាប្រើក្នុងសៀវភៅនេះ

ដើម្បីសំរួល ដល់ការពិនិត្យការចាប់ខុសចូន នៃកំណាព្យទាំង
ឡាយក្នុងសៀវភៅនេះ ខ្ញុំសូមប្រើសញ្ញាខ្លះៗ ដូចខាងក្រោម ៖

ក) សុំប្រើលេខ 123456... ជំនួសសញ្ញាពងត្រី ooooo
ដែលធ្លាប់តាមុន ។

ខ) សូមប្រើសញ្ញា ៣ សម្រាប់ ប្រើក្នុងគំនូសបញ្ជាក់ពី
ទំនាក់ទំនងឯបទនីមួយ ។ ។

១- វណ្ណំ : គឺព្យញ្ជនៈដូចគ្នា ដូចពាក្យ : កល: កិច្ច
កោង ប្រើសញ្ញា

២ ចូន : គឺស្រៈ + ប្រកបដូចគ្នា ដូចពាក្យ : មិត្ត. គិត
ពិត ប្រើសញ្ញា 

៣ - ផ្ដុំ : គឺ ព្យញ្ជនៈ + ស្រៈប្រកបដូចគ្នា គឺព្យាង្គ
ដដែល ដូចពាក្យ : ម៉ែត្រ . . . ម៉ែត្រ
ស្ដាយ . . . ស្ដាយ
ប្រើសញ្ញា

គ) សម្រាប់សេចក្ដីពន្យល់ សូមប្រើសញ្ញា ចិដែរ

១- វណ្ណំ : ព្យញ្ជនៈតែមួយ

២ - ចូន : ស្រៈ + ប្រកបដូច 

៣ - ផ្ដុំ : ព្យញ្ជនៈ + ស្រៈ + ប្រកបដូច 

www.yerngshare.blogspot.com

ឧទាហរណ៍ : បទកន្ត្រែបលោតជ្រាន់ ទ្វា

ឱកស្នេហ៍ពៅ ទៅស្នេហ៍ពិត គិតចង់ជួប . . .

តំនូសបញ្ជាក់ : 1 2 3 4 5 6 7 8 9



សេចក្តីពន្យល់ :



បានសេចក្តីថា ៖

ព្យាង្គទី ១	រណ្តំនិងព្យាង្គទី ៤
ព្យាង្គទី ២	ជ្រុនិងព្យាង្គទី ៥
ព្យាង្គទី ៣	ចូននិងព្យាង្គទី ៤
ព្យាង្គទី ៣	រណ្តំនិងព្យាង្គទី ៦
ព្យាង្គទី ៦	ចូននិងព្យាង្គទី ៧

www.yerngshare.blogspot.com

ប្រៀបស្រដៀង

www.yerngshare.blogspot.com

ប្រិយមិត្តអ្នកអានជាទីគោរព !

ក្នុងសៀវភៅ សិល្បៈតែងកំណាព្យ នេះមានកំណាព្យទាំងអស់ចំនួន ៥៣ បទ ប៉ុន្តែរៀបសរសេរ យើងរកឃើញបានត្រឹមតែ ៥០ បទ ប៉ុណ្ណោះ ។

ក្នុង ៥០ បទនេះ មានកំណាព្យបទពាក្យ ៨ យើងឃើញមានរៀបសរសេរ ២ ខែបនិងបទត្រីពធព័ន្ធ ក៏មាន ២ ខែបខុសគ្នាដែរ . . . យើងខ្ញុំបង្ហាញជូនក្នុងសៀវភៅនេះ ដើម្បីប្រិយមិត្តអ្នកអានជួយពិនិត្យពិចារណាបន្ថែមៗ

www.yerngshare.blogspot.com

បន្ទមបួន



ចំណាប់ចួន

⟶ 4 ឃ្លោ ៦ |=| 4 ឃ្លោ ៣ ល្បះជាមួយ

⟶ 4 ឃ្លោ ៤ ល្បះមុខ |=| 4 ឃ្លោ ២ |=| ៤ ឃ្លោ ៣ ល្បះបន្ត ។

ការសង្កត់សំឡេង

សង្កត់សំឡេងលើព្យាង្គ : 2 គ្រប់ឃ្លោ

សូមពិនិត្យអត្ថបទ

www.yerngshare.blogspot.com

បទរមួយ

ទឹកសាបមួយតក់ ស្រក់ក្នុងសមុទ្រ
ពិបាកបំផុត ឱងបន្សុះបានទុ ។

- ផ្តាំរុះរោយហើយ មិនដែលប្រែប្រាណ
ក្រពុំទៀតបាទ ដូចដើមវិញទេ ។

- ទេវីអូនអើយ អូនបានទេវីតែ
អាចផ្គូបវិញទេ ឬក៏យ៉ាងណា ? ។

- បងតែងសង្ឃឹម ក្នុងការសង្កា
ថាផ្គូបជីវិ។ ទាំងឥតសង្ឃឹម ។

www.yerngshare.blogspot.com

បឋមវជ្ឈាគត្ត



ចំណាប់ថ្នូន

→ ៨ ឃ្វា ១ | — | 4 ឃ្វា ២

៨ ឃ្វា ២ | — | ៨ ឃ្វា ៣ | — | 4 ឃ្វា ៤ ល្បះ ជាមួយគ្នា ។

→ ៨ ឃ្វា ៤ ល្បះមុន | — | ៨ ឃ្វា ១ | — | 4 ឃ្វា ២ ល្បះបន្ត ។

៨ ឃ្វា ២ | — | ៣ ឃ្វា ៣ | — | 4 ឃ្វា ៤ ល្បះបន្ត ។

ការសង្កត់សំឡេង

សង្កត់សំឡេង លើព្យាង្គ: ២ ៤ និង ៦ គ្រប់ឃ្វា

សូមពិនិត្យអត្ថបទ ។

www.yerngshare.blogspot.com

បទឧបថ្យាវត្ត

ត្រងោលចោលចាញ់លាបខ្លាញ់គីង្គក់
ត្រងោលផេកលក់គីង្គក់ល្ងចថើប
គេចាក់ចង្កេះពុំចេះរេសើប
គេខ្ចប់គេថើបធ្វើតែរាហ៊ឺ ។

- ជាអ្នកដឹកនាំត្រមោះធន្តី
ហានិយាយស្តីតបតិរេគ្គា
កូនទៅធ្វើខុសចេះប្តេជ្ញាសារុណា
អាណិតមេត្តាដូចទឹកអម្រឹត

សង្កេត :

បើយើងពិនិត្យហើយប្រៀបធៀប កំណាព្យបទមេបួន
និង បទឧបថ្យាវត្តនោះយើងឃើញថា កំណាព្យបទឧបថ្យាវត្តគឺជា
កំណាព្យដែលគួបយកកំណាព្យមេបួន ២ ល្អះ ឬមកនៅមួយល្អះ
ប៉ុណ្ណោះ ។

www.yerngshare.blogspot.com

បទភាវគតិ



ចំណាប់ចូន

⟶ 4 ឃ្លា ១ |=| 4 ឃ្លា ២ គ្រប់ល្បះទាំងអស់

4ឃ្លា ៣ |=| 4 ឃ្លា ៤ |=| 4 ឃ្លា ៦ ល្បះជាមួយគ្នា ។

⟶ 4 ឃ្លា ៧ ល្បះ ខុ១ |=| 4 ឃ្លា ៣ |=| 4 ឃ្លា ៥

|=| 4 ឃ្លា ៦ ល្បះ បន្ត ។

ការសង្កត់សំឡេង

សង្កត់សំឡេងលើព្យាង្គ : 2 និង 4 គ្រប់ឃ្លា ។

www.yerngshare.blogspot.com

បទភាវគតិ

- មុសក្នុងលោកា

រាល់រូបអាក្បាំ ស្លាប់ខ្ចិលាមក តែតាមការពិត
ជីវិតគំរក់ ស្តាយថង់លាមក រឹវក់សព្វថាន ។

- មនុស្សខ្លាចក្តីស្លាប់

តែមនុស្សគិចចាប់ ស្តាយស្លាប់ត្រប់ក្រាណា ខ្វះស្លាប់ខ្លួលស្លាប់
ឃ្លាស្លាប់តាអស់ថាន មនុស្សសូចុំន្មាន មិនខានពីស្លាប់ ។

- ស្លាប់ដំណង់លើ

ផ្ទៃតែលើភើ ផើកូចំណាប់ ខ្លាឥណាស់ការពិត
ដីវិការសំស្លាប់ ឮដូចមនុស្សខ្លាំងខាប់ សុទ្ធយ៉ាម៉ង់ម៉ាងហ្នឹង ។

- ឱលោកមនុស្សឆើយ

សតវត្សរ៍នេះហើយ ភ្លូវតែខំប្រឹង បើនេះថាចេះ
មិនដឹងកុំដឹង រឿងរាដូច្នឹង ថាយ៉ាងហ្នឹងទេវ ។

www.yerngshare.blogspot.com

បទព្រហ្មគីតិ



ចំណាប់ជួន

5 ឃ្លះ ១ | 3 ឃ្លះ ២ ត្រង់ល្ង:
6 ឃ្លះ ២ | 5 ឃ្លះ ៣ | 3 ឃ្លះ ៤ ។
6 ឃ្លះ ៤ ល្ង:ម្ដង | 6 ឃ្លះ ២ | 5 ឃ្លះ ៣
| 3 ឃ្លះ ៤ ល្ង:បន្ត ។

ការសង្កត់សំឡេង

ឃ្លះទី ១ និង ឃ្លះទី ៣ : សង្កត់សំឡេងលើព្យាង្គ 2
ឃ្លះទី ២ និង ទី ៤ : សង្កត់សំឡេងលើព្យាង្គ 3

www.yerngshare.blogspot.com

បទព្រហ្មគីតិ

នរមនុស្សដើរផ្លូវល្អ ផ្លូវដែកថ្នេរម្ទៀងដើមភ្នែក
អូសហ៊ុបទៀងច្រវែងចោត បានពីរគាត់ឆ្ងល់ពីបាកសាស់ ។

- បើចង់បានផ្លែផ្កា ក្អួតល្ងាអាចរហ័ស
ដាំឆ្នាំឃើញផលច្បាស់ ផ្លែខ្ចីចាំនុំបេះបាន ។

រីផលតំពីមនុស្ស ក្តឹបហើយទ្រុះចុះចាកឋាន
មិនងាយនុំបេះបាន ត្រូវតឹងតានច្រែនសិបឆ្នាំ ។

- ដូច្នេះត្រូវខិតខំ ស្តាប់ឱវាទនុំនាប្រចាំ
អប់រំច្រែនសិបឆ្នាំ ព្យាយាមដាំទីបសម្រេច ។

www.yerngshare.blogspot.com

បទពំនោល



ចំណាប់ជួន

6 ឃ្លា ១ | 4 ឃ្លា ២ | 2 ឃ្លា ៣ ល្បះដាមួយ ៖

6 ឃ្លា ៤ ល្បះមុខ | 6 ឃ្លា ១ | 4 ឃ្លា ២

| 2 ឃ្លា ៣ ល្បះបន្ត ។

ការសង្កត់សំឡេង

សង្កត់សំឡេងលើព្យាង្គ : 2 និង 4

សូមគន្លឹះអត្ថបទ . . .

www.yerngshare.blogspot.com

បទពំនោល

- ឧក្ខុនប្រុសស្រីចំណាប់ រីផ្កាឈើចាប់ ជាចង្ហាប់ជាទ្រព្យសិរី ។

- ផ្លូវច្នេះចូរក្ខុនប្រុសស្រី ផ្តិតផ្តង់ស្មារតី រៀនក្តីឈើចាប់កុំអាក់ ។

- ឈើជាតិនិងឈើវណ្ណៈ ពុះការគ្រោះថ្នាក់ ឧបសគ្គទុះញ៉ែមពិសី ។

- បើក្ខុនឈើខុរឯប្រុសស្រី ជាតិមានសៅរ៍ ទឹកដីរុងរឿងផ្តើមផ្តាច ។

www.yerngshare.blogspot.com

ឧទាហរណ៍លេខគាត



ចំណាប់ផ្តួន

→ 4 ឃ្លា ១ | 4 ឃ្លា ២ ត្រប់ល្បះ

6 ឃ្លា ២ | 4 ឃ្លា ៣ | 2 ឬ 4 ឃ្លា ៤ ។

→ 6 ឃ្លា ៤ ល្បះមុខ | 6 ឃ្លា ២ | 4 ឃ្លា ៣

| 2 ឬ 4 ឃ្លា ៤ ល្បះបន្ត ។

ការសង្កត់សំឡង

ឃ្លាទី ១ និង ឃ្លាទី ៣ : ត្រូវសង្កត់សំឡេងលើព្យាង្គ 2

ឃ្លាទី ២ និងទី ៤ : ត្រូវសង្កត់សំឡេងលើព្យាង្គ 2 និង 4

សូមពិនិត្យអត្ថបទ

 www.yerngshare.blogspot.com

ចតុបន្ទាលគាថ

- កំពូផសត្វខ្លា　　ហ្វូងពាលមំសាហារសត្វ
  គោងប្រុងប្រយ័ត្ន　　កុំការ៉ាត់ចិត្តឆៀងាស្លុត ។

- កំពូផលាក់ពុត　　ពំនិតសុំតទ្រុឌហ្វុត
  ពេលខ្សោយឆ្លើស្លុត　　ឫកពាស្រងូតរៀបសា ។

- អែនអនទន់ភ្លន់　　អាន់សិលស្ត្រមន្តធម៌អាថ៌
  ខ្លះពិចារណា　　មនុស្សទន់ចិន្តាឆៀសិប ។

- ខ្លាឃ្លានសាច់ស្រស់　　សាហាវទាំងអស់ពុំឈប់
  ឃើញយើងឆៀសិប　　សង្កៀបកាច់កខាំធ្លិ

- ប៉ុលពតសត្វខ្លា　　ខ្មែរគ្រប់ប្រជាប្រុសស្រី
  គិតវែងកុំខ្លី　　កុំខ្ចីឆៀខ្លាកាន់សីល ។

www.yerngshare.blogspot.com

បទភ្ជុំខ្ពស់លើសា



ចំណាប់ផ្តួន

→ 6 ឃ្លា ១ | 4 ឃ្លា ៦ | 2 ឃ្លា ៣ ល្បះជា
ផ្តួយគ្នា ។

→ 4 ឃ្លា ៣ ល្បះមុខ | ៦ ឃ្លា ១ | 4 ឃ្លា ៦
| 2 ឃ្លា ៣ ល្បះចុង ។

ការសង្កត់សំឡេង

សង្កត់សំឡេងលើព្យាង្គ : 2 និង 4

សូមពិនិត្យអត្ថបទ

www.yerngshare.blogspot.com

បទភុជង្គលីលា

- ចំណេះវិជ្ជាជាទ្រព្យ

សម្បត្តិល្អជាប់ ជាងទ្រព្យសម្ផាយ ។

- ទោមកមិនចាច់រេចស្ពាយ

ទោះនឹងចាយរាយ មិនងាយនឹងអស់ ។

ចាយច្រើនកើតច្រើនឥតខ្ចោះ

មិនដែលរីងខ្សោះ មិនអស់ខាតខាន ។

គ្មានចោរប្លន់លួចឆក់បាន

ជាទ្រព្យរុញច្រាន ឲ្យបានពន្ធី ។

